# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤១៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/ ១២៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៧ /៤១២ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរអាងទន្លេសាប (អ.អ.ទ.ស) ។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានតួនាទី និងភារកិច្ចដូចតទៅ ÷

- ទទួលបន្ទុកចាត់ការទូទៅ គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាព និងការងារប្រចាំថ្ងៃរបស់ អ.អ.ទ.ស
- ធ្វើទំនាក់ទំនង សហការ និងសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ ក្នុងតំបន់អាងទន្លេសាប ប្រកបដោយនិរន្តរភាព
- ផ្តល់ប្រឹក្សា តាមដានត្រួតពិនិត្យ និងចូលរួមវាយតម្លៃនូវការអនុវត្តរាល់សកម្មភាព និងគម្រោងនានារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងតំបន់អាងទន្លេសាប
- សិក្សា រាយការណ៍ និងជូនយោបល់ទៅប្រធាន អ.អ.ទ.ស នូវផលប៉ះពាល់នៃការអនុវត្តរាល់សកម្មភាព និងគម្រោងនានារបស់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានាដែលពាក់ព័ន្ធក្នុងដែនសមត្ថកិច្ចរបស់ អ.អ.ទ.ស
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អភិវឌ្ឍ អ.អ.ទ.ស ជូនគណៈកម្មាធិការប្រតិបត្តិពិនិត្យ មុននឹងដាក់ឆ្លង អ.អ.ទ.ស សម្រេច
- សិក្សាពីលទ្ធភាព និងវិធីសម្របសម្រួល ដើម្បីចូលរួមរៀបចំ និងអនុវត្តគម្រោងសាកល្បងក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ ស្របតាមយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការរបស់រាជរដ្ឋាភិបាល
- ប្រមូល វិភាគ ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មាន ទិន្នន័យ ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- បូកសរុបលទ្ធផលការងាររបស់ អ.អ.ទ.ស ជូនប្រធាន អ.អ.ទ.ស តាមកាលកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន អ.អ.ទ.ស ប្រគល់ជូន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ និង ការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានរចនាសម្ព័ន្ធ ដូចខាងក្រោម ÷

១- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២- នាយកដ្ឋានផែនការ និងសហប្រតិបត្តិការ

៣- នាយកដ្ឋានសម្របសម្រួលគម្រោងផែនសេដ្ឋកិច្ច

៤- នាយកដ្ឋានសម្របសម្រួលគម្រោងផែនសង្គមកិច្ច

៥- នាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មាន

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានក្រុមបង្គោលអាជ្ញាធរអាងទន្លេសាប ប្រចាំរាជធានី ខេត្ត ពាក់ព័ន្ធ។ អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរអាងទន្លេសាប ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

**មាត្រា ៤.-**

**នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ÷**

- ទទួលខុសត្រូវលើសេវាកម្មទូទៅក្នុងផ្នែករដ្ឋបាល និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទ អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស
- គ្រប់គ្រងត្រារបស់ អ.អ.ទ.ស
- ទទួលខុសត្រូវលើការងារ សំណុំលិខិត ឯកសារ លិខិតបទដ្ឋាន ច្បាប់ ឯកសារសម្ងាត់ ទំនាក់ទំនងរដ្ឋបាលគ្រប់ផ្នែក ការតម្កល់ឯកសារ សណ្តាប់ធ្នាប់ និងអនាម័យ
- បូកសរុប និងធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងារ របស់អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស
- គ្រប់គ្រងឯកសារ និងក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងការងារអភិវឌ្ឍធនធានមនុស្ស ក្នុងអគ្គលេខាធិការដ្ឋាន នៃ អ.អ.ទ.ស
- ទទួលបន្ទុករៀបចំកិច្ចប្រជុំ ឬសិក្ខាសាលា និងធ្វើរបាយការណ៍ ឬកំណត់ហេតុ
- រៀបចំគម្រោងថវិកា សម្ភារៈ និងមធ្យោបាយនានា ប្រចាំឆ្នាំរបស់ អ.អ.ទ.ស
- គ្រប់គ្រង និងបែងចែកសម្ភារបរិក្ខាររបស់ អ.អ.ទ.ស
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌរបស់ អ.អ.ទ.ស
- លើកគម្រោងជួសជុល ផ្គត់ផ្គង់ និងថែទាំចលនទ្រព្យ អចលនទ្រព្យ
- ប្រតិបត្តិថវិកាឱ្យបានត្រឹមត្រូវ ទៅតាមគោលការណ៍លទ្ធកម្ម និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារពាក់ព័ន្ធប្រាក់បៀវត្ស ស្មើប្រាក់ឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីរាជការ និងបុគ្គលិកក្នុង អ.អ.ទ.ស
- ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការប្រតិបត្តិ អ.អ.ទ.ស មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍនានា ក្នុងការប្រើប្រាស់ថវិកាសម្រាប់ដំណើរការ និងការអភិវឌ្ឍ អ.អ.ទ.ស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន។

**មាត្រា ៥.-**

**នាយកដ្ឋានផែនការ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ច ÷**

- សិក្សា និងចងក្រងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព[...] អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាបសម្រាប់រយៈពេលខ្លី មធ្យម និងវែង[...]

- ធ្វើទំនាក់ទំនង និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ក្នុងការរៀបចំ ចងក្រង និងអនុវត្តគោលការណ៍ បទដ្ឋាន គោលដៅ យុទ្ធសាស្ត្រ កម្មវិធី គម្រោង និងសកម្មភាពដើម្បី ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- សហការ និងសម្របសម្រួលរាល់ទស្សនៈ និងការងាររបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍនានាដែលគាំទ្រ ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីកៀរគរ និងវិភាជន៍មូលនិធិសម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាបតាមការជាក់ស្តែង
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃ ការប្រើប្រាស់មូលនិធិ ដែលគាំទ្រដោយដៃគូអភិវឌ្ឍនានា ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ តំបន់អាងទន្លេសាប
- រៀបចំផ្ទាល់ និងចូលរួមរៀបចំកិច្ចព្រមព្រៀង ពិធីសារសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាមួយភាគីដៃគូអភិវឌ្ឍនានា
- តាមដានត្រួតពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់ នៃការអនុវត្តគម្រោងនានា ទាំងវិស័យជំនាញ និង អន្តរវិស័យ ដែលបាន និងកំពុងដំណើរការ ក្នុងដែនសមត្ថកិច្ចរបស់ អ.អ.ទ.ស
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពទូទៅ ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍក្នុងតំបន់អាងទន្លេសាប ជូន អ.អ.ទ.ស តាមកាលកំណត់
- សហការជាមួយគ្រប់ដៃគូអភិវឌ្ឍ និងក្រសួង ស្ថាប័នជំនាញជាតិ ដើម្បីបណ្តុះបណ្តាលមន្ត្រី រាជការ បុគ្គលិក និងអ្នកពាក់ព័ន្ធ អំពីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន ។

មាត្រា ៦.-

**នាយកដ្ឋានសម្របសម្រួលគម្រោងផែនសេដ្ឋកិច្ច មានតួនាទី និងភារកិច្ច ÷**

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី គម្រោង និងផែនការសកម្មភាព ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ក្នុងបរិបទផែនសេដ្ឋកិច្ច សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយមានកិច្ចសហការជាមួយបណ្តាក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- ចូលរួម និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញក្នុងផែនសេដ្ឋកិច្ច ក្នុងការរៀបចំគោល នយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានា ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ អាងទន្លេសាប
- តាមដានត្រួតពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់នៃការអនុវត្តគម្រោងសេដ្ឋកិច្ចនានា ដែលបាន និងកំពុង ដំណើរការក្នុងដែនសមត្ថកិច្ចរបស់ អ.អ.ទ.ស

- សម្របសម្រួលការអនុវត្តគម្រោងសេដ្ឋកិច្ចនានា របស់បណ្តាក្រសួង ស្ថាប័នជំនាញ និងដៃគូអភិវឌ្ឍន៍ ដើម្បីភាពរលូន ភាពប្រទាក់ក្រឡាគ្នា ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- សិក្សា និងអនុវត្តគម្រោងសាកល្បង ដើម្បីអភិវឌ្ឍការងារសេដ្ឋកិច្ច ក្នុងតំបន់អាងទន្លេសាប តាមការចាំបាច់
- រាយការណ៍ពីវឌ្ឍនភាពរបស់គម្រោងផែនសេដ្ឋកិច្ចទាំងអស់ ដែលបាន និងកំពុងដំណើរការក្នុងតំបន់អាងទន្លេសាប ជូន អ.អ.ទ.ស តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន ។

**មាត្រា ៧.-**

**នាយកដ្ឋានសម្របសម្រួលគម្រោងផែនសង្គមកិច្ច មានតួនាទី និងភារកិច្ច ÷**

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី គម្រោង និងផែនការសកម្មភាព ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ក្នុងបរិបទផែនសង្គមកិច្ច សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយមានកិច្ចសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ
- ចូលរួម និងសម្របសម្រួល ជាមួយក្រសួង ស្ថាប័នជំនាញក្នុងផែនសង្គមកិច្ច ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានា ដើម្បីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- តាមដានត្រួតពិនិត្យ និងវាយតម្លៃពីផលប៉ះពាល់ នៃការអនុវត្តគម្រោងសង្គមកិច្ចនានា ដែលបាន និងកំពុងដំណើរការក្នុងផែនសមត្ថកិច្ចរបស់ អ.អ.ទ.ស
- សម្របសម្រួលការអនុវត្តគម្រោងសង្គមកិច្ចនានារបស់បណ្តាក្រសួង ស្ថាប័នជំនាញ និងដៃគូអភិវឌ្ឍ ដើម្បីភាពរលូន ភាពប្រទាក់ក្រឡាគ្នា ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- សិក្សា និងអនុវត្តគម្រោងសាកល្បង ដើម្បីអភិវឌ្ឍការងារសង្គមកិច្ចក្នុងតំបន់អាងទន្លេសាប តាមការចាំបាច់
- រាយការណ៍ពីវឌ្ឍនភាពរបស់គម្រោងផែនសង្គមកិច្ចទាំងអស់ ដែលបាន និងកំពុងដំណើរការក្នុងតំបន់អាងទន្លេសាប ជូន អ.អ.ទ.ស តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន ។

**មាត្រា ៨.-**

**នាយកដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មាន មានតួនាទី និងភារកិច្ច ÷**

- សហការជាមួយបណ្តាក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បីប្រមូល ចងក្រង និងផ្សព្វផ្សាយ ព័ត៌មាន ទិន្នន័យ ដែលទាក់ទងដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- សិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងដោយផ្ទាល់ នូវព័ត៌មាន និងទិន្នន័យ របស់គម្រោងនានា ដែលបានកំពុង និងគ្រោងអនុវត្តក្នុងតំបន់អាងទន្លេសាប

- សហការជាមួយបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីស្រាវជ្រាវ ចងក្រង និងលើកជាអនុសាសន៍ស្តីពីសក្តានុពលធនធានធម្មជាតិ និងបញ្ហាប្រឈមមុខនានា ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- អភិវឌ្ឍមជ្ឈមណ្ឌលប្រមូលផ្តុំព័ត៌មាន ទិន្នន័យបច្ចេកទេសនានា សម្រាប់បម្រើឱ្យការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- រៀបចំ និងផ្សព្វផ្សាយសៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី ផ្ទាំងរូបភាព និងខ្សែវីដេអូនានាស្តីពីសកម្មភាពគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប
- ផ្តល់ព័ត៌មាន ទិន្នន័យ តាមសំណូមពររបស់បណ្តាក្រសួង ស្ថាប័ន អាជ្ញាធរ និងអ្នកពាក់ព័ន្ធ
- ធ្វើការវិភាគព័ត៌មាន ទិន្នន័យ និងព្យាករពីស្ថានភាព និងការប្រែប្រួលទាំងឡាយ ក្នុងតំបន់អាងទន្លេសាប ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍ និងសេចក្តីសម្រេចចិត្តនានា
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.អ.ទ.ស ប្រគល់ជូន ។

**មាត្រា ៩.-**

**ក្រុមបង្គោលអាជ្ញាធរអាងទន្លេសាប ប្រចាំរាជធានី ខេត្ត មានតួនាទី និងភារកិច្ច ៖**

- ជួយសម្របសម្រួល និងសហការលើរាល់ការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសំណូមពរ និងការណែនាំរបស់ អ.អ.ទ.ស
- ផ្តល់ និងទទួលព័ត៌មានស្តីពីកម្មវិធី គម្រោង និងសកម្មភាពនានា ដែលបានកំពុង និងគ្រោងអនុវត្តក្នុងទិសដៅគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមបង្គោលអាជ្ញាធរអាងទន្លេសាប ដឹកនាំដោយអភិបាល ឬអភិបាលរងរាជធានី ខេត្ត មួយរូប ដោយមានមន្ត្រីបច្ចេកទេស ពីមន្ទីរជំនាញនានាជាជំនួយការ ដើម្បីធ្វើការកត់ត្រា ចងក្រងឯកសារព័ត៌មាន ពីកម្មវិធី គម្រោង និងសកម្មភាពនានា ដែលបានកំពុង និងគ្រោងអនុវត្តក្នុងទិសដៅគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ១០.-**

អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ ដែលជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស អាចមានអ្នកជំនាញការ ឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងាររបស់ខ្លួន។

ការបែងចែកលម្អិតអំពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ អ.អ.ទ.ស។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាធិការដ្ឋាន ក្នុងអគ្គលេខាធិការដ្ឋាននៃ អ.អ.ទ.ស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរអាងទន្លេសាប រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីសុំចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៧.អនក្រ.បក ចុះថ្ងៃទី ០៩...ខែ ឧសភា....ឆ្នាំ២០០៨

អង្គការលេខ របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរអាងទន្លេសាប

